ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ: ២៨៨ សជណ.សរ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**
**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីសំណើសុំគោលការណ៍ជ្រើសរើស ផ្តល់ថវិកាអមពានរង្វាន់ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ក្នុងការកំណត់ឈ្មោះពានរង្វាន់ជូន **នាយកសាលាល្អ និងគ្រូបង្រៀនល្អ** ប្រចាំឆ្នាំ។

**យោង ៖** លិខិតលេខ៣៦២ អយក.រប ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា៖ ចំពោះករណីសំណើសុំគោលការណ៍ជ្រើសរើស ផ្តល់ថវិកាអមពានរង្វាន់ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់ក្នុងការកំណត់ឈ្មោះពានរង្វាន់ជូន នាយកសាលាល្អ និងគ្រូបង្រៀនល្អ ប្រចាំឆ្នាំ រាជរដ្ឋាភិបាលបានយល់ព្រមជាគោលការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

ក. ជ្រើសរើសនាយកសាលាល្អចំនួន ០៣នាក់ និងគ្រូបង្រៀនល្អចំនួន ០៥នាក់ ជារៀងរាល់ឆ្នាំ។

ខ. កំណត់ឈ្មោះពានរង្វាន់ ថា "**សម្តេចតេជោ សែន**"។

គ- ផ្តល់ថវិកាអមពានរង្វាន់

គ-១- នាយកសាលាល្អ
- ១- ពានរង្វាន់លេខ ១ ចំនួន ៧ 000 000 រៀល។
- ២- ពានរង្វាន់លេខ ២ ចំនួន ៦ 000 000 រៀល។
- ៣- ពានរង្វាន់លេខ ៣ ចំនួន ៥ 000 000 រៀល។

គ-២- គ្រូបង្រៀនល្អ
- ១- ពានរង្វាន់លេខ ១ ចំនួន ៥ 000 000 រៀល។
- ២- ពានរង្វាន់លេខ ២ ចំនួន ៤ 000 000 រៀល។
- ៣- ពានរង្វាន់លេខ ៣ ចំនួន ៣ 000 000 រៀល។
- ៤- ពានរង្វាន់លេខ ៤ ចំនួន ៣ 000 000 រៀល។
- ៥- ពានរង្វាន់លេខ ៥ ចំនួន ៣ 000 000 រៀល។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រីជ្រាប និងទទួលអនុវត្តតាមការគួរ ។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**អ៊ុន វីរជាតិ**

**ចម្លងជូន:**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខអាន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់
- ឯកសារ-កាលប្បវត្តិ